00680257

E78

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តីលោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណារបស់លោក អៀង សារី ស្នើសុំមិនឲ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្គេក អ៊ាវ ហៅ "ឌុច" ជាភស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឲ្យ ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោកអៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង យូ ឧត្តរា

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 26 / 04 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់គាត់ (“មេធាវីការពារក្តី”) ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចថារាល់ចម្លើយក្រៅតុលាការទាំងអស់ ព្រមទាំងចម្លើយក្នុងតុលាការដែលមិនស្ថិតក្រោមសម្បថទាំងអស់របស់ ឌុច មិនអាចទទួលយកធ្វើជាភស្តុតាងបានឡើយ លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ដែលបានស្បថរួច ហើយត្រូវទទួលការសួរដេញដោលដោយពេញលេញពីភាគីបដិបក្ខ។ បន្ថែមលើនេះ ក្នុងករណីដែល ឌុច ត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ មេធាវីការពារក្តី ស្នើសុំឱ្យការិយាល័យសហព្រះរាជអាជ្ញា (“ក.ស.ព”) ព្រមទាំងអង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវរាល់ករណីទាំងអស់ដែល ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឌុច មិនបង្ហាញការពិតក្នុងចម្លើយរបស់គាត់។ សារណានេះមានសារៈសំខាន់ព្រោះ៖ ក) ការប្រើប្រាស់នូវរាល់ចម្លើយរបស់ ឌុច ដោយមិនផ្តល់ឱកាសដល់មេធាវីការពារក្តី ដើម្បីពិនិត្យមើលលើសច្ចភាពនៃចម្លើយទាំងនោះ គឺជាការរំលោភបំពានលើសិទ្ធិរបស់លោក អៀង សារី ក្នុងការតទល់គ្នា។ ខ) ព្រះរាជអាជ្ញាមិនត្រូវផ្តល់ដោយចេតនានូវភស្តុតាងដែលខ្លួនដឹងថាមិនពិតនោះឡើយ។ គ) ការបង្ហាញនូវករណីនានាដែល ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ចម្លើយរបស់ ឌុច មិនពិត ជាការចាំបាច់ដើម្បីធានានូវការការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវពេលវេលា និងលក្ខណៈគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំការពារខ្លួនគាត់។

## I ប្រវត្តិ

១. ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ បានដកស្រង់នូវចម្លើយរបស់ ឌុច ដែលរៀបរាប់អំពីភារកិច្ច និងសកម្មភាពរបស់គាត់នៅមន្ទីរស-២១ ព្រមទាំងទស្សនៈរបស់គាត់ចំពោះប្រព័ន្ធ, គោលនយោបាយ ព្រមទាំងគោលការណ៍ណែនាំនានា របស់របបកម្ពុជាប្រជាធិបតេយ្យ[1]។ ចម្លើយទាំងនេះធ្វើឡើងចំពោះ ក.ស.ច.ស[2] ចំពោះមុខអង្គ

[1] សូមមើលសំណុំរឿង អៀង សារី ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ D427, ERN: 00604508-00605246 (“ដីកាដំណោះស្រាយ”) កថាខណ្ឌ២១ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) បាននិយាយយោងដល់ការពណ៌នារបស់ ឌុច ចំពោះគោលនយោបាយ នៃចលនាកុម្មុយនីស្តក្នុងប្រទេសកម្ពុជា, ដូចដើងទំព័រខាងលើ កថាខណ្ឌ ៣៥ ដែល ឌុច បានពិភាក្សាពីតួនាទីរបស់

សារណារបស់លោក អៀង សារី ស្នើសុំមិនឱ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ជាភស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឱ្យ ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច

ជំនុំជម្រះសាលាដំបូង[3] ព្រមទាំងតាមរយៈចម្លើយជាលាយលក្ខណ៍អក្សរក្នុងអំឡុងដំណើរការនីតិវិធី សំណុំរឿង០០១[4]។

២. ក.ស.ព បានជំទាស់ទៅនឹងសច្ចភាពនៃចម្លើយទាំងនេះ នៅក្នុងសំណុំរឿង ០០១។ ក្នុងសេចក្តីសន្និដ្ឋានបញ្ចប់សវនាការដេញដោលរបស់ខ្លួន ក.ស.ពបានចោទសួរពីការទទួលខុសត្រូវរបស់ ឌុច ហើយបានបញ្ជាក់ថា “ជនជាប់ចោទបានស្នើឱ្យតុលាការពិចារណានូវទ្រឹស្តីពីរដែលមិនមានការជំពាក់ជំពិនគ្នា (ហើយទាំងពីរនេះ មិនគួរឱ្យជឿជាក់បាន)”[5] ព្រមទាំងថា ចម្លើយរបស់ ឌុច ទាក់ទងបញ្ហាថាតើគាត់មានសិទ្ធិ

---

គណកម្មាការមជ្ឈិម និងគណកម្មាការអចិន្ត្រៃយ៍ នៃបក្សកុម្មុយនីស្តកម្ពុជា, ដូចជើងទំព័រខាងលើ កថាខណ្ឌ៥៣ ដែល ក.ស.ច.ស បានដកស្រង់សម្តីរបស់ ឌុច ដែលពណ៌នាពីមុខងារនៃមន្ទីរស-៧១ “ការពារមន្ទីរមជ្ឈិម និងកម្មាភិបាលនៃមន្ទីរនេះ ទទួលភ្ញៀវ ទូរគមនាគមន៍ ភ័ស្តុភារ ស្បៀង ការដឹកជញ្ជូន”, សូមមើលផងដែរ ដូចជើងទំព័រខាងលើ កថាខណ្ឌ៦១ ដែល ក.ស.ច.ស បានដកស្រង់សម្តី ឌុច ដែលបានអះអាងថា មន្ទីរ៧៨០ គឺជាស្នាក់ការនៃ “មេដឹកនាំបក្ស”។

[2] សូមមើលជាឧទាហរណ៍ ដូចជើងទំព័រខាងលើ កថាខណ្ឌ២១ ដែលដកស្រង់ការសួរចម្លើយ ឌុច នៅចំពោះមុខ ក.ស.ច.ស “នាដើមទសវត្សន៍ឆ្នាំ១៩៦០ ប.ព.ខ បានបង្កើតកងការពារសម្ងាត់ ដើម្បី ការពារកម្មាភិបាល... រួមទាំងដើម្បីកម្ទេចខ្មាំង”។ ឌុចអះអាងថា គោលនយោបាយនេះត្រូវបានអនុម័ត... “ដើម្បីអូសទាញកម្លាំងដែលស្ទាក់ស្ទើរ អព្យាក្រឹត្យ កម្លាំងមិនឃោរឃៅ ឯកោ ហើយកម្ទេចកម្លាំងដែលសេសសល់”។

[3] សូមមើលជាឧទាហរណ៍ សំណុំរឿង កាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារិក កិច្ចដំណើរការនីតិវិធី សវនាការ “ឌុច” ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ E1/35.1, ERN: 00344105-00344224 (“ប្រតិចារិក ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩”)។ ទំព័រ ៦៤។

[4] សូមមើលជាឧទាហរណ៍ សំណុំរឿង កាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល របស់មេធាវីការពារក្តី ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ E159/8, ERN: 00401125-00401140។

[5] សូមមើលសំណុំរឿង កាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ដីកាសន្និដ្ឋានបញ្ចប់សវនាការដេញដោល របស់សហព្រះរាជអាជ្ញា ដោយមានឧបសម្ព័ន្ធពី ១-៥។ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ D288/6.159/9, ERN: 00400521-00400678។

អំណាចក្នុងការបញ្ជាឲ្យសម្លាប់អ្នកទោស នៅមន្ទីរស-២១ ឬអត់នោះគឺ "ពុំមែនជារឿងរ៉ាវពិតឡើយ"[6]។

៣. ក.ស.ព បានលើកឡើងថា ចម្លើយរបស់ ឌុច ខ្វះនូវភាពគួរឲ្យជឿបាន ដោយផ្ដល់នូវឧទាហរណ៍ដូចតទៅ៖

a) នៅពេលដែលចោទសួរពីសិទ្ធិអំណាចក្នុងការបញ្ជាឲ្យសម្លាប់អ្នកទោស ជនជាប់ចោទបានអះអាងថា គាត់គ្មានជម្រើស ហើយអ្នកទោសទាំងអស់ត្រូវបានសម្លាប់ដោយមានការសម្រេចពី "ថ្នាក់លើ" ដូច្នេះការបញ្ជាឲ្យសម្លាប់ របស់គាត់ គឺគ្រាន់តែជាការបង្គ្រប់កិច្ចប៉ុណ្ណោះ។ ឌុចបានអះអាងថា ចំណារបញ្ជាឲ្យធ្វើទារុណកម្ម និងសម្លាប់ ត្រូវបានធ្វើឡើងក្រោមការត្រួតពិនិត្យផ្ទាល់របស់ សុន សេន ដែលគាត់និយាយជាមួយតាមទូរស័ព្ទជារៀងរាល់ថ្ងៃ។ នៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា នេះពុំមែនជារឿងរ៉ាវពិតឡើយ[7]។

b) ជនជាប់ចោទបានអះអាងថា សុន សេន បានទទួលរបាយការណ៍សួរចម្លើយរបស់ជនជាប់ចោទ ហើយបន្ទាប់មកបានធ្វើការសម្រេចទៅលើរបាយការណ៍នោះ ដោយចេញបញ្ជាឲ្យមានការបោះសម្អាតជាមួយ ស៊ូម៉េត។ គាត់បានអះអាងបន្ថែមទៀតថា សុន សេន នៅតែបន្តចេញបញ្ជាឲ្យមានការបោសសម្អាត សូម្បីតែបន្ទាប់ពីគាត់បានចាកចេញទៅត្រួតពិនិត្យកងទ័ពនៅសមរភូមិក៏ដោយ។ នៅពេលសួរថាហេតុអ្វីបានជាឈ្មោះរបស់ សុន សេន មិនមាននៅលើសំបុត្រទាំងនោះ គាត់... មិនបានផ្ដល់ឲ្យនូវហេតុផលតក្កនុលោមចំពោះល្បិចកលបែបនោះឡើយ។ ក្រៅពីការអះអាងរបស់ជនជាប់ចោទ មិនមានភ័ស្ដុតាងគាំទ្រ

---

[6] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៧៦។

[7] ដូចជើងទំព័រខាងលើ។

សារណារបស់លោក អៀង សារី ស្នើសុំមិនឲ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ជាភ័ស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឲ្យ ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច

ទ្រឹស្តីនៃតួនាទីទាបនៅក្នុងការបោសម្អាតនេះទេ - ភ័ស្តុតាងបានបង្ហាញផ្ទុយពីនេះយ៉ាងច្បាស់[8]។

c) ការអះអាងរបស់ជនជាប់ចោទថា គាត់មិនបានដឹងអំពីការធ្វើទារុណកម្មលើ កែ គឹមហួតនោះ គឺជាការកុហកទាំងស្រុង។ ទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ កែ គឹមហួត និងការពិតដែលថាគាត់បានទទួល និងធ្វើចំណាររលើរបាយការណ៍សួរចម្លើយនោះ ហើយបែរជាមិនបានអានរបាយការណ៍នោះ គឺមិនអាចទទួលយកបានឡើយ[9]។

d) នៅក្នុងឱកាសជាច្រើនក្នុងអំឡុងពេលសវនាការ នៅពេលប្រឈមមុខទៅនឹងសំណួរជាច្រើន លើបញ្ហាស្តីពីអំណាចរបស់គាត់ក្នុងការចេញបញ្ជា, អំពីឆន្ទៈរបស់គាត់, អំពីចេតនា និងកម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្មផ្សេងៗ ជនជាប់ចោទបានផ្តល់សក្ខីកម្មដោយមិនពេញលេញដោយគេចវេះ និងដែលធ្វើឱ្យយល់ច្រឡំ[10]។

e) នៅក្នុងអំឡុងពេលនៃការស៊ើបសួរ និងសវនាការជំនុំជម្រះក្តីទាំងមូលជនជាប់ចោទបាន៖ ក) បដិសេធមិនបកស្រាយការពិតទាំងស្រុង នៃព្រឹត្តិការណ៍ទាំងឡាយនៅក្នុង និងនៅជុំវិញមន្ទីរស-២១ ទេ ខ) ស្វះស្វែងបង្រួមតួនាទី និងការចូលរួមដោយផ្ទាល់របស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ ឱ្យមកតូច និង គ) បញ្ជាក់អះអាងថា មិនអាចនឹក

---

[8] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៩៩។

[9] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២២០។

[10] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤២៥។

ឃើញឡើងវិញ ឬបដិសេធមិនឆ្លើយទៅនឹងសំណួរនានាលើបញ្ហាទាំងឡាយដែលនៅក្នុងរង្វង់នៃការដឹងរបស់គាត់[11]។

f) ទោះជាយ៉ាងណាក៏ដោយ ការព្រមទទួលពិរុទ្ធភាពរបស់ជនជាប់ចោទមិនមានតម្លៃជាការទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនមួយពេញលេញ និងច្បាស់លាស់នោះទេ។ គាត់ទទួលសារភាពថា ខ្លួនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅ មន្ទីរស-២១។ ប៉ុន្តែគាត់អះអាងនៅពេលដំណាលគ្នាថា ខ្លួនមិនអាចប្រឆាំងនឹងបំណងថ្នាក់លើរបស់ខ្លួនបានឡើយ និងគ្រាន់តែបានធ្វើតាមបញ្ជារបស់ពួកគេតែប៉ុណ្ណោះ។ កិច្ចខិតខំប្រឹងប្រែងរបស់គាត់ ដើម្បីកាត់បន្ថយឲ្យបានជាអប្បបរមានូវតួនាទីដ៏មធ្យមរបស់គាត់ និងដែលមានសារៈសំខាន់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មនានា គឺវាផ្ទុយពីភ័ស្តុតាងសក្ខីកម្ម និងភ័ស្តុតាងជាក់ស្តែងដែលបញ្ជាក់ផ្សេងពីនេះ[12]។

g) នៅក្នុងដំណាក់កាលផ្សេងៗនៅក្នុងសវនាការជំនុំជម្រះក្តី ជាទូទៅនៅពេលបានប្រឈមទៅនឹងភ័ស្តុតាង ឬទៅនឹងការតាំងសំណួរទាក់ទងទៅនឹងការពាក់ព័ន្ធដោយផ្ទាល់របស់គាត់ គាត់បានគេចវេះ និងជាញឹកញាប់មិនបានឆ្លើយតបឲ្យបានចំសំណួរនោះទេ។ ទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ ជនជាប់ចោទបានអះអាងទាំងរៀចរេរថា ខ្លួនមិនមានលទ្ធភាពនឹងឃើញព្រឹត្តិការណ៍សំខាន់ៗឡើងវិញទេ (ដែលផ្ទុយពីការចងចាំយ៉ាងឥតខ្ចោះរបស់ខ្លួន ទៅលើបញ្ហាទាំងឡាយដែលមានប្រយោជន៍ដល់ខ្លួនគាត់ក៏ដោយ) ឬក៏គាត់បានផ្តល់ដំណើររឿងមិនគួរ

[11] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤២៦។

[12] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤៣៣។

ឲ្យជឿ ដែលមិនស៊ីសង្វាក់គ្នាជាមួយនឹងភ័ស្តុតាងនៅចំពោះមុខ តុលាការ[13]។

h) ការអះអាងរបស់ជនជាប់ចោទដែលថា គាត់ត្រូវបានគេបញ្ជាថាត្រូវធ្វើ អ្វីខ្លះជារៀងរាល់ថ្ងៃ ពីសំណាក់ក្រុមមន្ត្រីជាន់ខ្ពស់មួយក្រុមតូច ដែល ទទួលបន្ទុកលើការងារទូទាំងប្រទេសនោះ គឺមិនអាចទទួលយកបាន ទេ។ ការអះអាងទាំងនេះ គឺជាការមិនពិត[14]។

៤. នៅក្នុងផ្នែកមួយទាំងមូល នៃបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹង សាលក្រមរបស់ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០១ បានផ្តោតជាសំខាន់ទៅ លើ ការសហការជាមួយតុលាការ "ទៅតាមការជ្រើសរើស និងទៅតាមការឆក់ ឱកាស"[15]៖

នៅក្នុងដំណាក់កាលខុសគ្នាក្នុងពេលជំនុំជម្រះ ជាធម្មតានៅពេលប្រឈមនឹង ភ័ស្តុតាង ឬសំណួរនានា ដែលទាក់ទងនឹងការពាក់ព័ន្ធរបស់ខ្លួនផ្ទាល់ ចុងបណ្តឹង សាទុក្ខបានគេចវេស និងនៅស្ងៀមជាញឹកញាប់មិនឆ្លើយទៅនឹងសំណួរទាំង នោះ។ ត្រង់បញ្ហានេះដែរ ចុងបណ្តឹងសាទុក្ខ ក៏បានអះអាងថា ខ្លួននឹកមិនឃើញ នូវហេតុការណ៍សំខាន់ៗទាំងនេះ (ផ្ទុយទៅវិញចុងបណ្តឹងសាទុក្ខបានចងចាំយ៉ាង

---

[13] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤៤០។

[14] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤៨២។

[15] សំណុំរឿង កាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីរបស់ កាំងហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ F10, ERN: 00613385-00613450 កថាខណ្ឌ ៧០។

ល្អចំពោះបញ្ហាទាំងឡាយដែលមានប្រយោជន៍ដល់គាត់) ឬ ក៏បានរៀបរាប់ដោយ មិនទំនង ដែលមិនស៊ីសង្វាក់គ្នាទៅនឹងភ័ស្តុតាងនៅចំពោះមុខតុលាការ[16]។

៥. ក្នុងសាលក្រមលើសំណុំរឿង ០០១ អង្គជំនុះជម្រះសាលាដំបូងយល់ឃើញថា ឌុច មិនបង្ហាញការពិតនៅក្នុងចម្លើយរបស់គាត់ ព្រោះក្នុងចំណោមការយល់ឃើញនានា ឌុចមានការទទួលខុសត្រូវចំពោះអំពើនៅ មន្ទីរស-២១ លើសពីអ្វីដែលគាត់បាន សារភាព[17] ហើយ៖

> ជនជាប់ចោទបានអះអាងថា ឈ្មោះរបស់ សុន សេន និងក្រោយមកឈ្មោះរបស់ នួន ជា មិនត្រូវបានបញ្ចូលក្នុងការឆ្លើយឆ្លងនោះទេ ព្រោះដើម្បីលាក់បាំងពីការ ចូលរួមរបស់ពួកគេ។ ប៉ុន្តែគាត់បានអះអាងទៀតថា រាល់ការទំនាក់ទំនងទាំងអស់ ត្រូវបានពួកគាត់ដឹង ឬណែនាំ ហើយគាត់ទទួលបានលិខិតឆ្លើយឆ្លងនេះដោយ ផ្ទាល់ពីថ្នាក់លើរបស់គាត់។ ការពន្យល់របស់ជនជាប់ចោទដែលថា លិខិតទាំង អស់នេះត្រូវបានប្រគល់មកឲ្យគាត់ផ្ទាល់តាមរយៈ សុន សេន នោះគឺមិនអាចជឿ បានទេ ព្រោះថាជនជាប់ចោទបានទទួលដំណឹងពី ស៊ូ ម៉េត តាមរយៈសំបុត្រមួយ ចំនួនថា អ្នកជាប់ឃុំនឹងត្រូវបញ្ជូនទៅឲ្យគាត់នៅល្ងាចនោះ។ ការពិតដែលថាគាត់ រង់ចាំទទួលអ្នកជាប់ឃុំ ហើយត្រៀមខ្លួនជាស្រេចដើម្បីទទួលអ្នកទាំងនោះ បញ្ជាក់ថា សំបុត្រទាំងនោះត្រូវបានផ្ញើផ្ទាល់ទៅឲ្យគាត់...[18]

៦. ទោះបីជា ក.ស.ព បានលើកជំទាស់ដដែលៗថា ឌុច មិនបង្ហាញការពិត ហើយអង្គ ជំនុះជម្រះសាលាដំបូងយល់ឃើញថា គាត់មិនបង្ហាញនូវការពិតឲ្យបានល្អិតល្អន់ក៏

---

[16] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៦៩។

[17] សំណុំរឿង កាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមលើសំណុំរឿង ០០១ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ E188, ERN: 00572517-00572797 (“សាលក្រម”) កថាខណ្ឌ ៥៩៧។

[18] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៧០។

ដោយ ក៏ក.ស.ពនៅតែកំណត់ឈ្មោះគាត់ជាសាក្សីប្រកបដោយសក្ដានុពលសម្រាប់សំណុំរឿង០០២ដែរ[19]។

## II ច្បាប់ជាធរមាន

### ក សិទ្ធិតទល់មុខគ្នាជាមួយសាក្សី

៧. មាត្រា១៣(១) នៃកិច្ចព្រមព្រៀងបានចែងថា៖ "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពល រដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្ដី។ សិទ្ធិបែបនេះជាពិសេស រួមមាន... សិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក"។

៨. មាត្រា៣៥ថ្មី នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក បានចែងថា៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយឆ្នាំ១៩៦៦... ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នា និងភ័ស្តុតាងដាក់បន្ទុកដែរ"។

៩. មាត្រា៨៧(២) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក បានចែងថា៖ "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភ័ស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល"។

១០. មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") បានចែងថា៖ "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្ដី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្ដីមានសមត្ថកិច្ចឯករាជ្យ និងមិន

---

[19] សំណុំរឿង អៀង សារី ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ បញ្ជីអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់សហព្រះរាជអាជ្ញា តាមវិធាន ៨០ ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ ១, ២, ៣, ៣ក, ៤ និង ៥ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, E9/4, ERN: 00640752-00640778 ឧបសម្ព័ន្ធ៣ ទំព័រ ៨។

សារណារបស់លោក អៀង សារី ស្នើសុំមិនឱ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ជាភ័ស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឱ្យ ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច

លំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី"។ មាត្រា១៤(៣)(ង) ចែងបន្ថែមថា "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ... ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក"។

## ខ ការត្រៀមលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន

១១. មាត្រា១៣(១) នៃកិច្ចព្រមព្រៀងបានចែងថា "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេស រួមមាន... សិទ្ធិមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន"។

១២. មាត្រា៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក បានចែងថា "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ... មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន"។

## គ សមភាពនៃការតទល់ក្តីគ្នា

១៣. មាត្រា ២១(១)(ក) បានចែងថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

# III ឧទ្ធិករណ៍

សារណារបស់លោក អៀង សារី ស្នើសុំមិនឲ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ជាភ័ស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឲ្យ ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច

**ក ការប្រើប្រាស់នូវរាល់ចម្លើយរបស់ ឌុច ដោយមិនផ្តល់ឱកាសដល់មេធាវីការពារក្តី ដើម្បីពិនិត្យមើលលើសច្ចភាពនៃចម្លើយទាំងនោះ គឺជាការរំលោភបំពានលើសិទ្ធិរបស់លោក អៀង សារី ក្នុងការតតាំងគ្នា**

១៤. ជាការចាំបាច់ ដែលចម្លើយរបស់ ឌុច មិនត្រូវបានទទួលយកធ្វើជាភស្តុតាងសម្រាប់សំណុំរឿង ០០២ ទេ លុះត្រាតែគាត់បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ដែលបានស្បថរួច ហើយត្រូវទទួលយកការសួរដេញដោល ក្នុងសំណុំរឿងនេះ។ សិទ្ធិត្រួតពិនិត្យលើភស្តុតាង គឺជាសិទ្ធិជាមូលដ្ឋានតាមផ្លូវច្បាប់ ដែលបានការពារដោយមាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។ សិទ្ធិនេះក៏ត្រូវបានការពារដោយវិធាន ៨៧(២) ដែលចែងថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល"

១៥. អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ បានអនុវត្តវិធាន ៨៧(២) នៅពេលដែលខ្លួនបដិសេធមិនទទួលយកចម្លើយរបស់សាក្សីពីររូប ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះ៖ ក) សាក្សីបានបាត់បង់ជីវិតតាំងពីមុនពេលសវនាការបានចាប់ផ្តើម ហើយ ឌុច មិនអាចត្រួតពិនិត្យទៅលើសច្ចភាពនៃចម្លើយរបស់សាក្សីទាំងនោះ ខ) ចម្លើយទាំងនោះមិនបានធ្វើឡើងក្រោមសម្បថនោះឡើយ និង គ) ចម្លើយនិយាយយោងទៅដល់អំពើឧក្រិដ្ឋ ព្រមទាំងការប្រព្រឹត្តឧក្រិដ្ឋរបស់ឌុច[20]។ ចម្លើយរបស់ ឌុច គឺមានលក្ខណៈប្រហាក់ប្រហែលទៅនឹងចម្លើយរបស់សាក្សី មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូង

---

[20] សំណុំរឿង កាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ E43/4, ERN: 00332849-00332857 កថាខណ្ឌ ១៣ ដល់១៧។

បដិសេធ។ ទីមួយ ចម្លើយរបស់ ឌុច មិនធ្វើឡើងក្រោមសម្បថនោះទេ[21]។ ទីពីរ ចម្លើយរបស់ ឌុច បាននិយាយយោងទៅលើអំពើឧក្រិដ្ឋ និងការប្រព្រឹត្តឧក្រិដ្ឋរបស់លោក អៀង សារី[22]។ ទីបី ចម្លើយរបស់ ឌុច ត្រូវបានការពារមិនឱ្យមានការជំទាស់ពីមេធាវីការពារក្តី។ លុះត្រាតែ ឌុច ធ្វើការផ្តល់សក្ខីកម្មដោយស្ថិតក្រោមសម្បថ ព្រមទាំងទទួលការសួរដេញដោល ទើបលោក អៀង សារីមានឱកាសដើម្បីពិនិត្យមើលលើសច្ចភាពនៃចម្លើយរបស់ ឌុច។ ដូចដែលមេធាវីការពារក្តីបានលើកឡើងពីមុនមកហើយ ឌុចត្រូវតែស្បថ ប្រសិនបើគាត់ត្រូវធ្វើសក្ខីកម្ម។ ច្បាប់កម្ពុជា ក៏ដូចជាច្បាប់អ.វ.ត.ក តម្រូវឱ្យសាក្សីធ្វើការស្បថ លើកលែងតែសាក្សីនោះស្ថិតនៅក្នុងករណីលើកលែងដែលមានតិចតួចប៉ុណ្ណោះ។ ប៉ុន្តែ ឌុច មិនស្ថិតនៅក្នុងករណីលើកលែងទាំងនោះឡើយ[23]។

---

[21] សំណុំរឿង កាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង ប្រតិចារិកដំណើរការនីតិវិធី- សវនាការ “ឌុច” ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩, E1/5.1, ERN: 00301476-00301548 ទំព័រ៥។

[22] ប្រតិចារិក ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ៦៤។

[23] សូមមើលវិធាន ២៤ ដែលចែងថា សាក្សីខាងក្រោមត្រូវឆ្លើយដោយមិនចាំបាច់ធ្វើសម្បថ តែតាមការយល់ឃើញរបស់មេធាវីការពារក្តី ឌុច មិនស្ថិតក្នុងលក្ខខណ្ឌលើកលែងទាំងនេះទេ៖

ក-ឪពុក ម្តាយ និងបុព្វញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី

ខ-កូនស្រី កូនប្រុស និង បច្ឆាញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី

គ-បងប្អូនប្រុសស្រីរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី

ឃ-បងប្អូនថ្លៃប្រុសស្រីរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី

ង-សហព័ទ្ធរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ទោះបីពួកជាបានលែងលះគ្នាហើយក៏ដោយ និង

ច-ក្មេងដែលមានអាយុតិចជាង ១៤ (ដប់បួន)ឆ្នាំ។

សូមមើលផងដែរក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៥៦។

សារណារបស់លោក អៀង សារី ស្នើសុំមិនឱ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ជាភស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឱ្យ ក.ស.ព និង អង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច

១៦. ក្នុងសំណុំរឿង០០១ សិទ្ធិក្នុងការសួរដេញដោលលើសាក្សី ដែលបានផ្តល់ចម្លើយពីមុនត្រូវបានអង្គជំនុំជម្រះសាលាដំបូង ធ្វើការអះអាងរួចមកហើយ[24]។ ការណែនាំនានាអាចស្វែងរកបានតាមរយៈយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដោយសារតែឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ក៏ដូចជាទំហំនៃភ័ស្តុតាងដែលត្រូវប្រើប្រាស់គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់និង *Blagojević & Jokić* បានពិចារណា ថាតើជនជាប់ចោទត្រូវបានដកហូតសិទ្ធិរបស់គាត់ក្នុងការសួរដេញដោលឬអត់ ប្រសិនបើចម្លើយដែលផ្តល់ដោយជនជាប់ចោទណាមួយដែលស្ថិតក្នុងការជំនុំជម្រះរួម ត្រូវទទួលយកធ្វើជាភ័ស្តុតាង ហើយអ្នកផ្តល់ចម្លើយនោះប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់គាត់[25]។ ទោះបីជាលោក អៀង សារី មិនត្រូវបានជំនុំជម្រះរួមជាមួយ ឌុច នៅក្នុងសំណុំរឿង ០០២ ក៏ដោយ ក៏ក.ស.ព បានចោទប្រកាន់ថា ឌុច ជាមួយលោក អៀង សារី បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម[26]។ ប្រសិនបើចម្លើយរបស់ ឌុច ត្រូវបានទទួលយកធ្វើជាភ័ស្តុតាង សិទ្ធិរបស់លោក អៀង សារីក្នុងការសួរដេញដោលអាចត្រូវបានការពារ តែក្នុងករណីដែល ឌុច ផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ហើយត្រូវទទួលយកការសួរដេញដោលតែប៉ុណ្ណោះ។

---

[24] សំណុំរឿង កាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៩ E26, ERN: 00290318-00290322 កថាខណ្ឌ៩.២ បានកត់សម្គាល់ថាការសួរចម្លើយដោយភាគីនានាតម្រូវឱ្យមាន "ការសួរតទល់ជាមួយនិងចម្លើយរបស់សាក្សីនានា ដែលត្រូវស្តាប់ចម្លើយនៅក្នុងសវនាការ" នឹងត្រូវធ្វើ "ក្នុងអំឡុងពេលដែលសាក្សីនោះត្រូវមកធ្វើសក្ខីកម្ម"។

[25] រដ្ឋអាជ្ញា តទល់និង *Blagojević & Jokić* IT-02-60-T សេចក្តីសម្រេចលើសំណើរដ្ឋអាជ្ញាសុំឱ្យបញ្ជាក់លម្អិតលើសេចក្តីសម្រេចដោយផ្ទាល់មាត់ ទាក់ទិននឹងការទទួលយកចម្លើយរបស់ជនជាប់ចោទ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ កថាខណ្ឌ១៨។ ជាចុងក្រោយអង្គជំនុំជម្រះសាលាដំបូង មិនត្រូវបានតម្រូវឱ្យចេញសេចក្តីសម្រេចចំពោះសំណួរមួយនេះឡើយ ព្រោះចម្លើយទាំងនោះត្រូវបានរកឃើញថា មិនអាចទទួលយកបាន។ ដូចជើងទំព័រខាងលើ កថាខណ្ឌ២៨។

[26] សំណុំរឿង អៀង សារី ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ D3, ERN: 00141011-00141166 កថាខណ្ឌ៨។

**ខ ក.ស.ព មិនត្រូវផ្តល់ភស្តុតាងដែលខ្លួនដឹងថាមិនពិតនោះឡើយ**

១៧. ប្រសិនបើ ឌុច ត្រូវផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ក.ស.ពត្រូវតែបង្ហាញនូវរាល់ករណីជាក់លាក់ ដែលខ្លួនជឿជាក់ថាចម្លើយរបស់ ឌុច មិនពិត។ ក្នុងនាមជាការិយាល័យឯករាជ្យមួយនៃ អ.វ.ត.ក[27] ការិយាល័យសហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវលើកតម្កើងកិច្ចដំណើរការនីតិវិធីដែលប្រកបដោយយុត្តិធម៌ ស្មើភាព និងមានប្រសិទ្ធិភាព។ កាតព្វកិច្ចនេះគឺអនុលោមតាមវិធាន ២១(១)(ក) ដែលចែងថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"[28]។

១៨. ក.ស.ពក៏មានកាតព្វកិច្ចរារាំងមិនលើកយកនូវសាក្សីរូបណាដែលខ្លួនដឹងថា នឹងប្រព្រឹត្តិបំពានលើសម្បថ។ តាមច្បាប់កម្ពុជា ព្រះរាជអាជ្ញាត្រូវមាន "ភាពស្មោះត្រង់ និងយុត្តិធម៌" ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន[29]។ ចំណែកក្រមសម្រាប់ព្រះរាជអាជ្ញា (Crown Prosecutor) ចែងប្រហាក់ប្រហែលគ្នាពី "ការជំនុំជម្រះដោយយុត្តិធម៌ និងមានប្រសិទ្ធិភាព"[30]។ ចំណែកសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់រដ្ឋអាជ្ញា បានបញ្ជាក់ថារដ្ឋអាជ្ញាត្រូវបំពេញតួនាទីរបស់

---

[27] សូមមើលវិធាន១៣។

[28] សូមមើល អង្គការសហប្រជាជាតិ គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី, អនុម័តិដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការរារាំងឧក្រិដ្ឋកម្ម និងកាប្រព្រឹត្តិចំពោះជនល្មើស Havana, ប្រទេសគុយបា ថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០, គោលការណ៍ ១២ ដែលតម្រូវឲ្យមេធាវី "រក្សានូវកិត្តិយស និងសេចក្តីថ្លៃថ្នូរក្នុងអាជីពរបស់ខ្លួន ក្នុងនាមជាភ្នាក់ងារនៃរដ្ឋបាលតុលាការ"។

[29] ក្រមសីលធម៌សម្រាប់ចៅក្រម ព្រះរាជាណាចក្រកម្ពុជា ទំព័រ២។

[30] ក្រមសម្រាប់ព្រះរាជអាជ្ញា (Crown Prosecutor) ខែ កុម្ភៈ ឆ្នាំ ២០០៩ មាត្រា២.១។

ខ្លួន "ដោយយុត្តិធម៌ មានសង្កតភាព និងឆាប់រហ័ស" ដើម្បីធានានូវដំណើរការយុត្តិធម៌ និងការប្រព្រឹត្តទៅដោយរលូនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[31]។

១៩. មេធាវីត្រូវ "នៅគ្រប់កាលៈទេសៈ គោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈ មនុស្សធម៌ និងភាពគួរសមថ្លៃថ្នូរ" តាមច្បាប់កម្ពុជាស្តីពីសីលធម៌វិជ្ជាជីវៈរបស់អ្នកច្បាប់[32]។ ដើម្បីជួយដល់តុលាការក្នុងការស្វែងរកឯកសារការពិត មេធាវីជាចាំបាច់មិនត្រូវបង្ហាញនូវរាល់ភ័ស្តុតាងដែលខ្លួនដឹងថាមិនពិតនោះឡើយ[33] ហើយជាពិសេសពីព្រោះអង្គជំនុំជម្រះសាលាដំបូងផ្អែកលើភ័ស្តុតាងដែលបានដាក់នៅចំពោះមុខខ្លួន ក្នុងការចេញសាលក្រម[34]។ ក្រមសីលធម៌វិជ្ជាជីវៈមេធាវីដែលបំពេញការងារនៅតាមតុលាការព្រហ្មទណ្ឌអន្តរជាតិនានា បានចែងថារដ្ឋអាជ្ញា "មិនត្រូវដាក់នូវភ័ស្តុតាងដែលខ្លួនដឹងថាមិនត្រឹមត្រូវ ដោយចេតនានោះឡើយ"[35]។ ក.ស.ព មានលទ្ធភាពកំណត់នូវផ្នែកជាក់លាក់នានាក្នុងចម្លើយរបស់ ឌុច ដែលខ្លួនមិនអាចទុកចិត្តបាន ព្រោះក្នុងសំណុំរឿង០០១ ក.ស.ព បានបញ្ជាក់ជាសាធារណៈថា ឌុច មិនអាចទុកចិត្តបាន។ យ៉ាងហោចណាស់វានឹងបង្កនូវការព្រួយបារម្ភ ហើយអាច

---

[31] សេចក្តីណែនាំស្តីពីតួនាទីរបស់រដ្ឋអាជ្ញា មហាសន្និបាតអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការរារាំងឧក្រិដ្ឋកម្ម និងការប្រព្រឹត្តិចំពោះជនល្មើស Havana, ប្រទេសគុយបា ថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០ មាត្រា ១២។

[32] ក្រមសីលធម៌នៃមេធាវី ដែលបានចុះក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៦។

[33] Stuart Coghill, *Resource Guide to the Criminal Law of Cambodia*, INTERNATIONAL HUMAN RIGHTS LAW GROUP CAMBODIAN DEFENDERS PROJECT, 2000, § 3.102

[34] វិធាន ៨៧(៣)។

[35] ក្រមសីលធម៌វិជ្ជាជីវៈរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៧(៥) សូមមើលផងដែរ បទបញ្ជាផ្ទៃក្នុងតុលាការ ICTY លេខ២ បទដ្ឋាននៃវិជ្ជាជីវៈរដ្ឋអាជ្ញា មាត្រា២(ង) បទបញ្ជាផ្ទៃក្នុងរដ្ឋអាជ្ញា បទដ្ឋាននៃវិជ្ជាជីវៈ មាត្រា ២(ង)។

ជាការខុសសីលធម៌វិជ្ជាជីវៈ បើសិន ក.ស.ព ពឹងផ្អែកទៅលើចម្លើយរបស់ ឌុច ដោយមិនបានបង្ហាញថា តើខ្លួនយល់ឃើញថាផ្នែកណាខ្លះនៃចម្លើយនោះដែលមិនពិត។

២០. ជាថ្មីម្តង យើងអាចដកស្រង់យកសេចក្តីណែនាំពីយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានាបាន។ ក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់* *GAA* ដែលជារឿងក្តីប្រមាថនៅចំពោះមុខតុលាការ ICTY អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សក្ខីកម្មមិនពិតត្រូវចាត់ទុកថាជា "ការប្រឈមដោយផ្ទាល់ចំពោះសុច្ចរិតភាពនៃប្រព័ន្ធតុលាការ"[36]។ ក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Lubanga អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ បានបង្គាប់ឱ្យរដ្ឋអាជ្ញាបង្ហាញនូវ អន្តរការីរបស់អ្នកស៊ើបអង្កេត ដើម្បីឱ្យអន្តរការីបង្ហាញនូវភ័ស្តុតាងថាតើខ្លួនបានប្រឌិតភ័ស្តុតាង ឬអត់ ក្រោយពីមានសាក្សីមេធាវីការពារក្តីមួយចំនួនបានបញ្ជាក់ថា អន្តរការីទាំងនោះ បញ្ជាឱ្យសាក្សីផ្តល់នូវសក្ខីកម្មមិនពិត[37]។ ក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Tadic* សាលាឧទ្ធរណ៍ តុលាការ ICTY យល់ឃើញថាបទបង្ហាញរបស់សាក្សីដែលមេធាវីបានដឹងថា បានផ្តល់ចម្លើយដែលមិនពិត គឺស្មើនឹងការប្រមាថអង្គជំនុំជម្រះ ព្រោះអំពើនេះ "បានរារាំង, ធ្វើឱ្យមានបុរេនិច្ឆ័យ ឬក៏រំលោភបំពានទៅលើរដ្ឋបាលតុលាការនៃអង្គ

---

[36] *រដ្ឋអាជ្ញា តទល់នឹង* *GAA*, ICTR-07-90-R77-I, សាលក្រម និងការផ្តន្ទាទោស ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ១០។

[37] *រដ្ឋអាជ្ញា តទល់នឹង* *Lubanga*, ICC-01/04-01/06 សេចក្តីសម្រេចដោយមានកោសលប់ លើករណីអន្តរការី ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៤០ និង៤១។ សេចក្តីសម្រេចនេះត្រូវបានចេញ ព្រោះតែសាក្សីមួយចំនួនបានអះអាងថាអន្តរការីរូបនេះបានផ្តល់ជាសំណូកដល់បុគ្គលដែលមិនធ្លាប់ធ្វើជាទាហានកុមារ ឱ្យនិយាយកុហកអ្នកស៊ើបអង្កេតថា ខ្លួនគឺជាអតីតសមាជិកនៃ Union des Patriotes Congolais ("UPC")។ បុគ្គលទាំងនេះ មួយចំនួនត្រូវបានគេរាយការណ៍ថាបានបន្តផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីរបស់រដ្ឋអាជ្ញា ហើយពួកគេបានអះអាងថាខ្លួនត្រូវបានគេកំណែនយោធា ទៅក្នុងក្រុម UPC។

ជំនុំជម្រះ”[38]។ មេធាវីបានលើកឡើងនូវករណី “ដែលគាត់បានដឹងថាមិនពិត ទាក់ទិននឹងស្ថានទម្ងន់ដែលត្រូវផ្ដល់ឱ្យដល់ចម្លើយសាក្សី”[39]។ ដូចគ្នានេះ ក.ស.ព បានធ្វើការកត់សម្គាល់យ៉ាងច្រើនទៅលើចម្លើយមិនពិតរបស់ ឌុច ក្នុងសំណុំរឿង០០១ ហើយបានលើកយកនូវឧទាហរណ៍ជាក់លាក់ខ្លះមកបង្ហាញជូនតុលាការថែមទៀត។ ប្រសិនបើ ក.ស.ព ស្នើសុំដាក់បុគ្គលណាម្នាក់ក្នុងបញ្ជីសាក្សី ដែលបុគ្គលនោះធ្លាប់បានផ្ដល់ចម្លើយមិនពិត វាជាការរំលោភទៅលើកាតព្វកិច្ចសីលធម៌របស់ខ្លួន ហើយក៏បំពានទៅលើរដ្ឋបាលតុលាការ របស់អង្គជំនុំជម្រះដែរ ព្រោះសាក្សីដែលគេដឹងឮថាបានផ្ដល់នូវសក្ខីកម្មមិនពិត ត្រូវមានឱកាសផ្ដល់សក្ខីកម្មម្ដងទៀត។ ប៉ុន្តែបញ្ហានេះអាចកែសម្រួលបាន ប្រសិនបើ ក.ស.ព ផ្ដល់នូវបញ្ជីនៃចម្លើយទាំងឡាយណាដែលខ្លួនជឿជាក់ថាមិនពិត។

២១. លើសពីនេះទៅទៀត លោក អៀង សារី មានសិទ្ធិជាមូលដ្ឋានទទួលបាននូវពេលវេលានិងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន[40]។ ដើម្បីធានាថាសិទ្ធិទាំងនេះត្រូវបានការពារ ក.ស.ព ត្រូវតែជូនដំណឹងដល់មេធាវីការពារក្ដី នូវរាល់ចម្លើយទាំងឡាយណាដែល ក.ស.ព ជឿជាក់ថាមិនពិត មុនពេលដែលភាគីនានាផ្ដល់នូវបញ្ជីសម្ភារៈ ដែលត្រូវពឹងផ្អែក[41]។ ដើម្បីការពារក្ដីលោក អៀង សារី មេធាវីការពារក្ដីត្រូវតែដឹងថាឯកសារណាដែលត្រូវផ្ដល់អាទិភាព ហើយពេលណាដែលត្រូវ

---

[38] *រដ្ឋអាជ្ញា តទល់នឹង* សាលក្រមលើបទចោទស្ដីពីការប្រមាថលើអតីតមេធាវី លោក Milan Vujin ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ១៨ និង១៦០។

[39] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៦០។

[40] កិច្ចព្រមព្រៀង មាត្រា១៣(១), ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក មាត្រា៣៥ថ្មី , ICCPR មាត្រា១៤។

[41] សំណុំរឿង អៀង សារី ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, E9, ERN: 00635754-00635759 កថាខណ្ឌ៦ ចែងថា “ភាគីត្រូវផ្ដល់ផងដែរដោយមិនឱ្យលើសពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នូវ៖ ក. សេចក្ដីសង្ខេបនៃអង្គហេតុ ដែលសាក្សីនឹងត្រូវធ្វើសក្ខីកម្ម”។

ជំទាស់។ ករណីដែលមេធាវីការពារក្តីមិនបានដឹងថាតើចម្លើយណាខ្លះដែល ក.ស.ព ពិចារណាថាមិនពិតនោះ នឹងរារាំងមេធាវីការពារក្តីមិនឲ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំសម្រាប់កិច្ចសវនាការ ព្រោះមេធាវីការពារក្តីពិតជាត្រូវចំណាយ ពេលក្នុងការសម្រេចលើបញ្ហានេះដោយខ្លួនឯង។

**គ អង្គជំនុំជម្រះសាលាដំបូង ត្រូវបង្ហាញនូវរាល់ករណីទាំងអស់ដែលខ្លួនយល់ឃើញថា ចម្លើយរបស់ ឌុច មិនពិត ដើម្បីធានាថាលោក អៀង សារី មាន ពេលវេលានិងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន**

២២. ប្រសិនបើ ឌុច ត្រូវផ្តល់សក្ខីកម្មនោះ អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវផ្តល់ដល់ភាគីនានានូវការយល់ឃើញរបស់ខ្លួន ទាក់ទិនដល់ការមិនបង្ហាញការពិតរបស់ ឌុច មុនពេលដែល ឌុច ត្រូវផ្តល់សក្ខីកម្មសម្រាប់សំណុំរឿង ០០២។ ការបង្ហាញបែបនេះ គឺស្របជាមួយនឹងគោលដៅរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស្វែងរកការពិត[42] ហើយវាក៏ជួយដល់ភាគីនានាក្នុងការកំណត់អាទិភាពនៃសម្ភារៈរបស់ខ្លួន ក៏ដូចជាជួយដល់ការសួរដេញដោលទៅលើ ឌុច ផងដែរ។ អង្គជំនុំជម្រះសាលាដំបូងក៏ពឹងផ្អែកផងដែរទៅលើចម្លើយរបស់ ឌុច សម្រាប់ការសម្រេចលើសាលក្រមរបស់ខ្លួន ក្នុងសំណុំរឿង ០០១[43]។ ការបង្ហាញនេះ ក៏ជាការបង្ហាញថាចម្លើយរបស់ ឌុច ណាខ្លះដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាពិត និងចម្លើយណាខ្លះដែលខ្លួនយល់ឃើញថាមិនពិត។ ទោះបីជាក្នុងសាលក្រមបានបង្ហាញនូវករណីជាក់លាក់នានាដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាចម្លើយរបស់ ឌុច មិនពិតក៏ដោយចុះ[44] ក៏

---

[42] សូមមើលវិធាន ៨៥(១), ៨៧(៤)។

[43] សូមមើលជាឧទាហរណ៍ សាលក្រម កថាខណ្ឌ១២១ ដែលនិយាយយោងដល់ការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ដើម្បីរកឲ្យឃើញថាតើ ឌុច ចាប់ផ្តើមគ្រប់គ្រង មន្ទីរស២១ ចាប់តាំងពីពេលណា។ សូមមើលផងដែរកថាខណ្ឌ ១៣១, ១៣៨, ១៤៣, ១៤៤, ១៧៧, ១៩៦, ២០១, និង ២១១។

[44] សូមមើលឧទាហរណ៍ ដូចដើងទំព័រខាងលើ កថាខណ្ឌ១៤៩។

ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង មិនបានបញ្ជាក់ថាករណីដែលបានបង្ហាញទាំងនេះគឺរាប់បញ្ចូលគ្រប់ករណីទាំងអស់ដែលខ្លួនយល់ឃើញថា ចម្លើយរបស់ ឌុច មិនពិត។ យើងស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះសេចក្តីណែនាំបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការយល់ឃើញរបស់ភាគី ចំពោះករណីនានាដែលបង្ហាញពីភាពមិនស្មោះត្រង់របស់ ឌុច។

**អាស្រ័យហេតុនេះ** សហមេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងមេត្តាសម្រេចថា រាល់ចម្លើយទាំងអស់របស់ ឌុច មិនត្រូវបានទទួលយកធ្វើជាភស្តុតាងនោះឡើយ លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សីដែលបានស្បថរួច ព្រមទាំងទទួលយកការសួរដេញដោល។ ករណីដែល ឌុច ត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា **បង្គាប់** ឱ្យក.ស.ព បង្ហាញនូវរាល់ករណីទាំងអស់ដែលខ្លួនពិចារណាថា ចម្លើយរបស់ ឌុច មិនពិត ហើយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង **បង្ហាញ** នូវរាល់ករណីនានា ដែលខ្លួនយល់ឃើញថា ចម្លើយរបស់ ឌុច នៅក្នុងសំណុំរឿង ០០១ មានភាពមិនពិតប្រាកដ។

សូមលោកចៅក្រមមេត្តាទទួលយកបណ្តឹងនេះដោយក្តីគោរព។

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៦** ខែ **មេសា** ឆ្នាំ **២០១១**